ច្បាប់គ្រប់គ្រងលេខ 8-09

គោលនយោលបាយពាក់ព័ន្ធទៅនឹងជនអន្តោប្រវេសន្តដែលទទួលបានសេវាកម្មទីក្រុង

ដោយយល់ឃើញថា,
ជនអន្តោប្រវេសន្តចូលរួមចំណែកនៅគ្រប់ផ្នែកទាំងអស់នៃវិស័យសេដ្ឋកិច្ច អប់រំ
និងវប្ប៉ធម៌ប្រចាំទីក្រុងហ្ស៊ីឡ្ការដែលហ្ស៊ីយ៉ា។;

ដោយយល់ឃើញថា,
ជនអន្តោប្រវេសន្តជាបុគ្គលមានការទាក់ទងទៅនឹងវិស័យសេដ្ឋកិច្ច វប្ប៉ធម៌
និងការរៀបចំសង្គម ម្ល៉ានិងថានៅក្នុងទីក្រុងហ្ស៊ីឡ្ការដែលហ្ស៊ីយ៉ាប៉ុណ្ណោះទេ
គឺនៅទូទាំងតំបន់នៃទីក្រុងហ្ស៊ីឡ្ការដែលហ្ស៊ីយ៉ា។ ;

ដោយយល់ឃើញថា, គោលនយោបាយរបស់ទីក្រុងគឺជំរុញអោយអ្នកទេសចរណ៍
អ្នកមានទីលំនៅស្ថិតនៅក្នុងទីក្រុង ដែលមានសិទ្ធិទទួលបាន និងមានតម្រូវការ
អាចប្រើប្រាស់នូវសេវាកម្មរបស់ខ្លួន ដែលក្នុងនោះរួមមានជនអន្តោប្រវេសន្តផងដែរ;

ដោយយល់ឃើញថា, រាល់បុគ្គលម្នាក់ៗគួរតែដឹងថា ពួកគេអាចស្វែងរកបាន
និងទទួលបានជំនួយពីដេប៉ាតឺម៉ង់ទីក្រុង ស្ថាប័ណ្ណផ្សេងៗ
ថ្មីបើស្ថានភាពខ្លួនពួកគេយ៉ាងណាក៏ដោយ
នឹងគ្មានហេតុផ្ទាល់អ៊ីវីធ្ជមានណាមួយទាក់ទងទៅនឹងការរស់នៅជាលក្ខណៈឯកជនរបស់ពួកគេ
;

ដោយយល់ឃើញថា,
ប្រជាពលរដ្ឋដែលជាជនអន្តោប្រវេសន្តរស់នៅក្នុងទីក្រុងមានតម្រូវការ ខាងជំនឿសារធារណៈ
នឹងភាពជឿជាក់ទៅលើរដ្ឋាភិបាលទីក្រុង; និង

ដោយយល់ឃើញថា, លទ្ធភាពក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ
គឺមានសារៈសំខាន់នៅក្នុងការប្រព្រឹត្តកិច្ចការតួនាទីរដ្ឋាភិបាល ដែលជួនកាលមានការពិបាក
ឬមិនអាចប្រព្រឹត្តទៅបាន
ប្រសិនបើគោលបំណងដែលត្រូវរក្សាការសម្ងាត់មួយចំនួនត្រូវបានធ្លាយចេញ;

ផ្នែកទីមួយ អាចទទួលយកសេវាកម្មរបស់ទីក្រុង។

រាល់សេវាកម្មទីក្រុងទាំងអស់ មិនរាប់បញ្ចូលសេវាកម្មដូចមានរៀបរាប់នៅខាងក្រោម
នឹងអាច ផ្តល់ទៅអោយប្រជាពលរដ្ឋទាំងអស់ដែលមានទីលំនៅនៅក្នុងក្រុងហ្ស៊ីឡ្ការដែលហ្ស៊ីយ៉ា
ទៅតាមច្បាប់ មានចែងជាធរមាន ថ្មីបើបុគ្គលនោះជាប្រជាពលរដ្ឋពេញសិទ្ធិ
ឬជាជនអន្តោប្រវេសន្តស្របច្បាប់ក៏ដោយ:

- សេវាកម្មប៉ូលីសពន្លត់អគ្គិភ័យ;
- សេវាកម្មសុខាភិបាល ដូចជាសេវាកម្មសង្គ្រោះបន្ទាន់
  ការថែទាំផ្ទះសាស្ត្រទ្ធ្ទ
  ការជួសជុលផ្ទះ ការព្យាបាល ការធ្វើតេស្តដោយផ្នែកទៅតាមប្រភេទជំងឺ;
- សេវាកម្មសុខភាពខាងស្មារតី;

- សេវាកម្មការពារកុមារ; និង
- ភាពទទួលបានការសម្របសម្រួលរបស់ទីក្រុង ដូចជាមជ្ឈមណ្ឌលកំសាន្តសប្បាយ និងបណ្ណាល័យ។

ផ្នែកទី២ ការសាកសួរព័ត៌មានពាក់ព័ន្ធទៅនឹងស្ថានភាពអន្តោប្រវេសន្ត

A. មិនអនុញ្ញាតអោយមន្ត្រី ឬនយោជករបស់ទីក្រុង
មន្ត្រីមានសមត្ថកិច្ចខាងផ្លូវច្បាប់
នឹងសាកសួរព័ត៌មានអំពីស្ថានភាពអន្តោប្រវេសន្តរបស់បុគ្គលណាម្នាក់ លើកលែងតែ:

(1) សំណុំឯកសារពីស្ថានភាពអន្តោប្រវេសន្តនៃបុគ្គលនោះ ត្រូវទាមទារអោយមានស្របច្បាប់ សំរាប់បំពេញអោយកម្មវិធីបញ្ជាក់ពីសេវាកម្ម ឬអត្ថប្រយោជន៍ដែលទទួលបាន ឬសេវាកម្មបណ្តោះអាសន្ន; ឬ

(2) មន្ត្រីនយោជកទាំងនោះទាមទារអោយមានសិទ្ធិស្របច្បាប់ក្នុងការសាកសួរព័ត៌មានពីស្ថានភាពអន្តោប្រវេសន្ត។

B. មន្ត្រីសមត្ថកិច្ចខាងផ្លូវច្បាប់ នឹងមិន:

(1) បញ្ឈប់ការសួរសំណួរ ចាប់ខ្លួន ឬឃាត់ខ្លួនបុគ្គលណាម្នាក់ដោយសារជាតិពន្ធ ប្រភពជនជាតិ ឬស្ថិតក្នុងស្ថានភាពឃ្លាមើលអន្តោប្រវេសន្ត;

(2) សាកសួរអំពីស្ថានភាពអន្តោប្រវេសន្តរបស់បុគ្គលម្នាក់ លើកលែងតែស្ថានភាពរបស់បុគ្គលនោះគឺជាការសំអាងនៃបទឧក្រិដ្ឋមួយ ដែលមន្ត្រីសមត្ថកិច្ចកំពុងធ្វើការស៊ើបអង្កេត ឬលើកលែងស្ថានភាពអន្តោប្រវេសន្តមានការទាក់ទងទៅនឹងការសំគាល់អត្តសញ្ញាណ របស់បុគ្គលនោះ ដែលត្រូវបានសង្ស័យថាកំពុងប្រព្រឹត្តបទឧក្រិដ្ឋ (ក្រៅពីស្ថានភាពនោះ ដូចជាជនបរទេសដែលគ្មានឯកសារគ្រប់គ្រាន់);

(3) សាកសួរអំពីស្ថានភាពអន្តោប្រវេសន្តរបស់ជនរងគ្រោះដោយបទឧក្រិដ្ឋ សាក្សី ឬអ្នកផ្សេងដែលជាអ្នកទូរស័ព្ទមក ឬមកដល់ស្ថានីយប៉ូលីសដើម្បីសុំជំនួយ; ឬ

(4) សាកសួរសំណួរដែលពាក់ព័ន្ធទៅនឹងស្ថានភាពអន្តោប្រវេសន្តក្នុងគោលបំណងអនុវត្តច្បាប់អន្តោប្រវេសន្ត។

C. មន្ត្រីអនុវត្តច្បាប់នឹងបន្តសហប្រតិបត្តិការជាមួយរដ្ឋ
និងអាជ្ញាធរសហព័ន្ធផ្សេងៗក្នុងការចុះស៊ើបអង្កេត
និងការចាប់ខ្លួនបុគ្គលដែលជាប់មន្ទិលសង្ស័យពីបទឧក្រិដ្ឋណាមួយ។

ផ្នែកទី ៣ ព័ត៌មានសម្ងាត់

A. ដូចបានអនុវត្តក្នុងនេះ "ព័ត៌មានសម្ងាត់" បានន័យថាព័ត៌មានណាមួយដែលទទួល បាន និងរក្សាទុកដោយភ្នាក់ងារទីក្រុងដែលពាក់ព័ន្ធទៅនឹងស្ថានភាពអន្តោប្រវេសន្តរបស់បុគ្គលណាមួយ។

B. មន្ត្រី ឬនយោជិកមិនត្រូវធ្វើអោយធ្លាយចេញនូវព័ត៌មានសម្ងាត់ទាំងនេះ លើកលែងតែ:

(1) ព័ត៌មានដែលជាប់ទាក់ទងនោះត្រូវបានអនុញ្ញតអោយមានការធ្លាយចេញ និងមាន ជាលាយលក្ខអក្សរ ដែលត្រូវបានសរសេរជាភាសាមួយអាចយល់បានដោយបុគ្គលដែល អនុញ្ញាតនោះ ក្នុងករណីបុគ្គលនោះជា អនីតិជន ឬបើមិនដូច្នោះទេគឺបុគ្គលដែលគ្មានសិទ្ធិស្របច្បាប់ក្នុងការទទួលយកការគ្រប់គ្រងពីឱពុក ម្តាយ ឬអាណាព្យាបាលរបស់បុគ្គលនោះ។

(2) ច្បាប់តម្រូវអោយព័ត៌មានចេញទាំងនោះធ្លាយចេញ; ឬ

(3) ចំពោះព័ត៌មានបុគ្គលមានការទាក់ទងទាំងនោះត្រូវបានសង្ស័យដោយមន្ត្រី ឬនយោជិកទាំងនោះ ឬ ភ្នាក់ងាររបស់នយោជិក ឬមន្ត្រីភ្នាក់ងារទាំងនោះថាចូលរួមក្នុងសកម្មភាព បទឧក្រិដ្ឋ (ក្រៅពីស្ថានភាពនោះ ដូចជាជនបរទេសដែលគ្មានឯកសារគ្រប់គ្រាន់)។

ផ្នែកទី ៤ កាលបរិច្ឆេទសុពលភាព

ច្បាប់នេះនឹងចូលជាធរមានយ៉ាងឆាប់រហ័ស។

11/10/09

កាលបរិច្ឆេទ	ចៅហ្វាយក្រុង MICHAEL A. NUTTER